

# ការនិយាយធម្មតា និងការរីកចម្រើននៃភាសា

សូមប្រើវិធីខាងក្រោមនេះ ជាការណែនាំ នៅពេលដែលក្មេងរៀនប្រាស្រ័យទាក់ទងនៅក្នុងកម្រិតខុសៗគ្នា។សូមអញ្ជើញទៅជួបវេជ្ជបណ្ឌិតរបស់លោកអ្នក ឬគិលានុបដ្ឋាកសម្រាប់ថែទាំទារក បើសិនជាមានការបារម្ភ។

**តាំងពីពេលកើតទៅដល់អាយុ៣ខែ**

- ងាករកមើលសូរសព្ទ និងសំឡេងឮៗ, ឧ. ការបិទទ្វារឮសូរខ្លាំងៗ និងសំឡេងទូរស័ព្ទជាដើម។
- រៀនចេះនូវជំនាញរក្សាទំនាក់ទំនងតាមកែវភ្នែក(ប្រើភ្នែកសម្លឹងមើលមុខ ឬក៏តាមមើលរបស់អ្វីមួយដែលកម្រើកឬធ្វើចលនា)
- ប្រើសំឡេងយំស្រែកខុសៗគ្នាដើម្បីប្រាប់ឲ្យដឹងនូវការឈឺផ្សា, ឃ្លាន និងអស់កម្លាំងជាដើម។
- ចាប់ផ្តើមបញ្ចេញសំឡេងកូនង៉ា មានដូចជា អេអឺ អេអា និងការបញ្ចេញសំឡេងតែម្នាក់ឯង។
- សើចញញឹមនៅពេលឮលោកអ្នកនិយាយ(អាយុពី៤ទៅ៦អាទិត្យ)
- ចេះជំនាញប្តូរវេន មានដូចជាការធ្វើត្រាប់តាមលោកអ្នកនៅពេលលោកអ្នកបញ្ចេញសូរសព្ទអ្វីមួយ។

**អាយុពី៣ទៅ៦ខែ**

- បែរក្បាលទៅរកសូរសព្ទនិងសំឡេងមួយចំនួន, ឧ. នរណាម្នាក់ដើរចូលតាមទ្វារ ជាដើម។
- នៅគ្រាអាយុ៣ខែ- ទារកបញ្ចេញសូរសព្ទ និងប្រើសំឡេងកាន់តែច្រើនឡើងៗ។
- ញញឹមញឹកញយ ហើយសើចនៅក្នុងពេលថ្ងៃ។

**អាយុពី៦ទៅ៩ខែ**



- នៅគ្រាអាយុ៦ខែ-ទារកចាប់ផ្តើមបញ្ចេញសំឡេងកូនក្មេង មានដូចជា "ដាដា", "បាបា", "អាដា" ជាដើម។
- បែរក្បាលទៅរកសំឡេងហៅឈ្មោះរបស់ខ្លួន ហើយយល់នៅពេលដែលលោកអ្នកនិយាយថា "អត់ទេ" ។
- ធ្វើត្រាប់តាមនូវចលនាឬសកម្មភាពសាមញ្ញ មានដូចជាការគ្រវីដៃលាគ្នា និងការទះដៃជាដើម។
- ប្រើសំឡេងនិងសូរសព្ទរួមគ្នាកាន់តែច្រើន មានដូចជា "ម៉ាម៉ាម៉ា", "ដាដាដា" ជាដើម។
- ប្រើកាយវិការកាន់តែច្រើនឡើង មានដូចជាគ្រវីក្បាល ដើម្បីនិយាយថា "អត់ទេ" ជាដើម។

**អាយុពី៩ទៅ ១២ខែ**

- យល់នូវសំណួរសាមញ្ញ មានដូចជា "ប៉ានៅទីណា?" ជាដើម។
- ធ្វើតាមការបង្គាប់សាមញ្ញ ដោយមានជំនួយ មានដូចជា "ឲ្យបាល់នេះទៅម៉ាក់" ជាដើម។
- ប្រើសម្តីនិងសូរសព្ទជាច្រើនលាយគ្នា មានដូចជា "ប្រឹមៗ" , "ដាបាដាបាដាបា" ជាដើម។
- ចាប់ផ្តើមចង្អុលនិងបញ្ចេញសំឡេង ដើម្បីបង្ហាញនូវសេចក្តីត្រូវការ និងការចង់បាន។

**អាយុពី១២ទៅ១៨ខែ**

- ស្គាល់ យ៉ាងតិចណាស់ ក៏ផ្នែកមួយនៃរាងកាយដែរ មានដូចជាច្រមុះជាដើម។
- យល់ពាក្យជាច្រើន, ការបង្គាប់សាមញ្ញ និងសំណួរដែលតម្រូវឲ្យមានចម្លើយខ្លីៗ មាន/អត់, ឧ. "តើអ្នកចង់ញ៉ាំទឹកឬទេ?" ។
- ចាប់ផ្តើមប្រើពាក្យទោលតែឯង (ប្រហែលជា ១២ទៅ២០ពាក្យ)។
- ធ្វើត្រាប់តាមសូរសំឡេង មានដូចជា សំឡេងសត្វ និងយានយន្តដឹកជញ្ជូនជាដើម។

## **អាយុពី១៨ទៅ២៤ខែ**



- ស្គាល់ផ្នែកជាច្រើននៃរាងកាយ។
- យល់ការបង្គាប់កាន់តែច្រើន មានដូចជា "រើសឡាននោះមក...ឲ្យវាទៅប៉ា" ជាដើម។
- ប្រើពាក្យទោលតែឯង ពី២៥ ទៅ៥០ពាក្យ។
- ចាប់ផ្តើមផ្គុំពាក្យ២បញ្ចូលគ្នា ដូចជា "ឡានប៉ា", "ទឹកផ្លែឈើម៉ាក់" , "ទៅរថភ្លើង" ជាដើម។

## **អាយុ២ឆ្នាំ**

- ប្រើពាក្យពី ៥០ទៅ ២០០ពាក្យជាទៀងទាត់
- ចាប់ផ្តើមផ្គុំជាឃ្លា ដោយប្រើពាក្យពី២ទៅ៣ពាក្យរួមគ្នា មានដូចជា "ទឹកផ្លែឈើថែមទៀត", "ប៉ាទៅឡាន"ជាដើម។
- ឆ្លើយតបនឹងសំណួរសាមញ្ញ មានដូចជា "ស្អីគេហ្នឹង?" , "តើឆ្កែនៅទីណា?" ជាដើម។
- ធ្វើតាមការបង្គាប់ណែនាំសាមញ្ញ ដោយមានពាក្យសំខាន់២ មានដូចជា "ដាក់**ផ្លែប៉ោម**ទៅក្នុង**ថង់**" ជាដើម។

## **អាយុ ៣ឆ្នាំ**

- យល់ពាក្យផ្សេងៗគ្នា ពោលគឺពាក្យបញ្ជាក់ទីតាំង មានដូចជា "ក្នុង" , "លើ" , "ក្រោម" ជាដើម។
- សម្គាល់ដឹងនូវវត្ថុ/របស់ ដោយសារមុខងារ ពណ៌ និងទ្រង់ទ្រាយនៃវត្ថុទាំងនោះ មានដូចជា "តើបាល់ធំនោះមានពណ៌អ្វី?"។
- ប្រើឃ្លាប្រយោគមួយដែលផ្គុំឡើងដោយ៣ទៅ៥ពាក្យ, ឧ. "កូនក្រមុំតុក្កតាដេកហើយ ឥឡូវនេះ"។
- សួរសំណួរមួយចំនួន មានដូចជា "អ្វីហ្នឹង?" , "អ្នកណាហ្នឹង?", "ទីណាហ្នឹង?"។
- ប្រើពាក្យសម្តីច្បាស់ ភាគច្រើន ប្រហែលជា៧០% (សូរសំឡេងនៅមិនទាន់គ្រប់លក្ខណៈដោយនៅមានការលូតលាស់នៅឡើយ)។
- ប្រើរចនាសម្ព័ន្ធវេយ្យាករណ៍កាន់តែច្រើនទៅ ទោះជាឃ្លាប្រយោគទាំងអស់ ពុំមានលក្ខណៈត្រឹមត្រូវក្តី មានដូចជា៖
    - o "-ing" (តំណាងឲ្យបច្ចុប្បន្នកាល), ឧទាហរណ៍ "Mummy walking" (ម៉ាក់កំពុងដើរ)។
    - o ពហុវចនៈ (ច្រើនជាងមួយ), ឧទាហរណ៍ "two balls" (បាល់ពីរ)។

## **អាយុ៤ឆ្នាំ**

- ប្រើពាក្យជាច្រើន(ប្រមាណជា៩០០ពាក្យ) ដោយមានប្រហែលជា៤ពាក្យ ឬច្រើនជាងនេះ នៅក្នុងឃ្លាប្រយោគនីមួយៗ។
- យល់អំពីអត្ថន័យនៃ "ម៉ោងពេល" មានដូចជា ម្សិលមិញ, រដូវរងា, អាទិត្យមុន ជាដើម។
- ការប្រើវេយ្យាករណ៍ជាទូទៅមានភាពត្រឹមត្រូវ គ្រាន់តែមានកំហុសឆ្គងកើតមានឡើងម្តងម្កាលប៉ុណ្ណោះ។
- ពេលនិយាយម្តងៗ គឺគេអាចស្តាប់យល់បានភាគច្រើន– បានរៀននូវសូរសព្ទនៃពាក្យសម្តីភាគច្រើន។

## **អាយុ៥ឆ្នាំ**

- អាចធ្វើតាមការបង្គាប់បាន៣យ៉ាង, ឧ. "ងើបឈរ, ពាក់ស្បែកជើងរបស់អ្នក ហើយធ្វើដំណើរទៅឡាន"។
- ប្រើឃ្លាប្រយោគ សមស្របតាមក្បួនវេយ្យាករណ៍ដោយមានពាក្យប្រមាណជា៦ ពាក្យឬច្រើនជាងនេះ។
- និយាយអំពីព្រឹត្តិការណ៍អតីតកាល បច្ចុប្បន្នកាល និងអនាគតកាល, ឧ. "យើងនឹងនាំគ្នាទៅសួនឧទ្យាននៅថ្ងៃស្អែក!"។
- យល់នូវប្រភេទផ្សេងៗជាច្រើននៃទស្សនទាន មានដូចជា សើម, ស្ងួត, ធំ, តូច, យឺត, លឿន ជាដើម។
- និយាយអំពីអារម្មណ៍ ហើយប្រាប់លោកអ្នកអំពីគំនិតទាំងពួង មានដូចជា "ខ្ញុំអត់សប្បាយចិត្ត – Jack នឹងមិនលេងជាមួយខ្ញុំទេ"។
- មិនថាមនុស្សដែលគេស្គាល់ ឬមនុស្សដែលគេមិនធ្លាប់ស្គាល់ទេ គឺអាចស្តាប់យល់នៅពេលដែលក្មេងនេះនិយាយ។


Stronger Families and Communities Strategy
An Australian Government Initiative

learning links
Helping Kids Learn

THE SMITH FAMILY
everyone's family

*Communities for Children is supported by the Australian Government under the Stronger Families & Communities Strategy*